# ឧបសម្ព័ន្ធទី៤៖ សេចក្តីណែនាំស្តីពីការស្នើសុំព្យួរកិច្ចសន្យាការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

- ចូលទៅកាន់គេហទំព័រ ***https://suspension.mlvt.gov.kh***
- Log in ដោយបំពេញ Username និង Password (យកលេខទូរស័ព្ទលេខរៀងទី១ នៃបញ្ជីឈ្មោះកម្មករនិយោជិតដែលរោងចក្រ សហគ្រាស គ្រឹះស្ថានបានធ្វើបច្ចុប្បន្នភាពមកក្រសួង)

## ជំហានទី ១

- បំពេញព័ត៌មានដូចជាឈ្មោះរោងចក្រ សហគ្រាស គ្រឹះស្ថាន, អាសយដ្ឋាន......
- ភ្ជាប់ (Upload) ឯកសារជា PDF ឬរូបភាព៖
  - ✓ វិញ្ញាបនបត្រពាណិជ្ជកម្ម
  - ✓ អាជ្ញាប័ណ្ណទេសចរណ៍
  - ✓ ប័ណ្ណពន្ធប៉ាតង់
  - ✓ វិញ្ញាបនបត្របញ្ជិការោងចក្រ សហគ្រាស គ្រឹះស្ថានក្នុង ប.ស.ស. (បើមាន)
  - ✓ កិច្ចព្រមព្រៀងអំពីនីតិវិធីទូទាត់ជាមួយកម្មករនិយោជិត
  - ✓ បញ្ជីបើកប្រាក់ឈ្នួលចុងក្រោយមុនពេលស្នើសុំព្យួរកិច្ចសន្យាការងារ

## ជំហានទី ២

- បំពេញមូលហេតុនៃការស្នើសុំព្យួរកិច្ចសន្យាការងារ
- បំពេញចំនួនកម្មករនិយោជិតដែលត្រូវស្នើសុំព្យួរកិច្ចសន្យាការងារ និងរយៈពេលព្យួរកិច្ចសន្យាការងារ

## ជំហានទី ៣

ជ្រើសរើសព្យួរកម្មករនិយោជិតទាំងអស់ ឬព្យួរមួយចំនួន

## ជំហានទី ៤

ជ្រើសរើសឈ្មោះកម្មករនិយោជិតដែលត្រូវស្នើសុំព្យួរកិច្ចសន្យាការងារ ចេញពីបញ្ជីឈ្មោះដែលមានក្នុងប្រព័ន្ធ (ប្រសិនបើព្យួរមួយចំនួន)

## ជំហានទី ៥

ចុចបញ្ចប់ការស្នើសុំព្យួរកិច្ចសន្យាការងារ

## ជំហានទី ៦

- ចូលទៅទំព័រដើម ដើម្បី៖
  - ✓ ទាញយកលិខិតស្នើសុំព្យួរកិច្ចសន្យាការងារ ដើម្បីចុះហត្ថលេខា និងត្រៀមប្រគល់ជូនអធិការការងារពេលចុះពិនិត្យផ្ទៀងផ្ទាត់
  - ✓ ទាញយកបញ្ជីឈ្មោះកម្មករនិយោជិតដែលស្នើសុំព្យួរកិច្ចសន្យាការងារ ដើម្បីយកទៅស្វែងរក និងបំពេញព័ត៌មាន ដូចជាលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ, លេខទូរស័ព្ទ, លេខប័ណ្ណសមាជិក ប.ស.ស. ...... និងឱ្យកម្មករនិយោជិតផ្តិតមេដៃបញ្ជាក់
- ក្រោយពេលអធិការការងារចុះពិនិត្យ និងមានស្នាមមេដៃត្រឹមត្រូវរបស់កម្មករនិយោជិត ត្រូវផ្ញើបញ្ជីឈ្មោះនេះជា Excel File និង Scan បញ្ជីឈ្មោះដែលបោះត្រា និងមានស្នាមមេដៃនេះជា PDF File មក ***E-mail: suspension@nea.gov.kh***

ព័ត៌មានបន្ថែម៖

លោក ងួន សទ្ធី (017 300 708) លោក លាង សុភ័គ (099 883 358) កញ្ញា បេន ល័ក្ខណា (012 752 745)